ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

ភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៧

ជាច្រើនឆ្នាំមកហើយ ប្រទេសកម្ពុជាគឺជាប្រធានបទនៃការធ្វើយុទ្ធនាការបំភ្លៃព័ត៌មាន ដឹកនាំដោយរដ្ឋាភិបាល និងអង្គការបរទេសមួយចំនួន ដែលបានមួលបង្កាច់អំពីតថភាព និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ក្នុងគោលបំណងបង្ហាញរូបភាពអវិជ្ជមានអំពីកម្ពុជា និងដាក់កំហុសមកលើរាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលសូមចេញផ្សាយនូវឯកសារក្រោមចំណងជើងថា "ប្រាប់ពីការពិត" ដើម្បីស្រាយបំភ្លឺ និងគូសបញ្ជាក់ការពិតលើបញ្ហារសើបទាំងឡាយ ។

********************

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

# កម្ពុជា លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ៖ ប្រាប់ពីការពិត

*"នេះមិនមែនជាលទ្ធិប្រជាធិបតេយ្យនោះទេ ការណ៍ដែលធ្វើលុយរាប់ប៊ីលានដុល្លារ ដើម្បីជម្រុញការផ្លាស់ប្តូររបបនៅក្រៅប្រទេសនោះ ។ នេះមិនមែនជាលទ្ធិប្រជាធិបតេយ្យ នោះទេការណ៍ដែលបញ្ជូនអង្គការមិនមែនរដ្ឋាភិបាលទៅសរសេរច្បាប់ឡើងវិញនោះ។"*
*លោក រ៉ុន ផូល អតីតសមាជិកសភាខុនក្រេសអាមេរិក (គណបក្សសាធារណរដ្ឋ)*

សម្រង់សំដីខាងលើនេះគឺជាការបញ្ជាក់ថា សហរដ្ឋអាមេរិកបានផ្តល់មូលនិធិគាំទ្រដល់សកម្មភាពក្រៅប្រទេស ក្នុងគោលបំណងដើម្បីផ្លាស់ប្តូររបបដែលរដ្ឋបាលអាមេរិកមិនពេញចិត្ត ។ សង្គមស៊ីវិលត្រូវបានគេប្រើប្រាស់ធ្វើជាមធ្យោបាយក្នុងការចាប់ផ្តើមដំណើរការធ្វើអោយប្រទេសរង្គោះរង្គើ ។ គឺជាករណីដែលកើតមានឡើងនៅប្រទេសអ៊ុយក្រែនក្នុងរដ្ឋបាលរបស់គណបក្សសាធារណរដ្ឋ និងនៅក្នុងប្រទេសហុនឌុយរ៉ាស់ក្នុងរដ្ឋបាលរបស់គណបក្សប្រជាធិបតេយ្យ ។ ជាច្រើនឆ្នាំមកហើយ កម្ពុជាបានទទួលរងនូវយុទ្ធនាការកាន់តែខ្លាំងឡើង ដឹកនាំដោយរដ្ឋាភិបាល និងអង្គការបរទេសមួយចំនួនដែលចង់បានការផ្លាស់ប្តូររបបនៅកម្ពុជា ទោះបីការណ៍នេះប្រឆាំងនឹងឆន្ទៈរបស់ប្រជាជនភាគច្រើននៅប្រទេសនេះក៏ដោយ ។ យុទ្ធនាការនេះពោរពេញទៅដោយការមូលបង្កាច់ការពិត ភូតកុហក ការបំប៉ោងបញ្ហាតូចតាច ក្នុងគោលបំណងបង្ខូចកេរ្តិ៍ឈ្មោះ និងដាក់កំហុសទៅលើស្ថាប័នបច្ចុប្បន្នដែលស្របច្បាប់ ។

រាជរដ្ឋាភិបាលកម្ពុជាចង់បំភ្លឺ និងបញ្ជាក់ការពិតអោយដាច់ស្រឡះតែម្តង។ជាបឋម រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្ខំចិត្តធ្វើនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម ៖

១) កម្ពុជាគឺជាប្រទេសអធិបតេយ្យ។ អធិបតេយ្យភាពនេះត្រូវតែទទួលបានការគោរពដោយពេញលេញ ។ ធម្មនុញ្ញអង្គការសហប្រជាជាតិបានបញ្ញត្តយ៉ាងច្បាស់ថា គ្មានរដ្ឋណាមួយមានសិទ្ធិទៅលូកលាន់ដោយផ្ទាល់ ឬ ដោយប្រយោល ទោះក្នុងហេតុផលណាក៏ដោយ នៅក្នុងកិច្ចការផ្ទៃក្នុង ឬ បញ្ហាដែលប៉ះពាល់ដល់បូរណភាពទឹកដី ឬ ឯករាជភាពនយោបាយរបស់ប្រទេសដទៃបានឡើយ (មាត្រា ២.៤, ២.៧) ។ ធម្មនុញ្ញអាស៊ានបានកំណត់យកការមិនលូកលាន់កិច្ចការផ្ទៃក្នុងរបស់រដ្ឋសមាជិកធ្វើជាគោលការណ៍មូលដ្ឋាន (មាត្រា ២.២ (e))។ នៅក្នុងកិច្ចព្រមព្រៀងទាក់ទងនឹងអធិបតេយ្យភាព ឯករាជភាពបូរណភាពនិងភាពមិនអាចរំលោភបំពានបាននៃដែនដី អព្យាក្រឹត្យភាព និងឯកភាពជាតិកម្ពុជា ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងសន្តិភាពគ្រប់ជ្រុងជ្រោយរបស់កម្ពុជា ដែលយើងហៅជាទូទៅថា កិច្ចព្រមព្រៀងទីក្រុង

ប៉ារីស រដ្ឋហត្ថលេខីទាំង ១៨ មានកាតព្វកិច្ចជាក់លាក់គឺ "ត្រូវចៀសវាងការលូកលាន់ទោះក្នុងទម្រង់ណាក៏ដោយ ទាំងផ្ទាល់ ឬ មិនផ្ទាល់នៅក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា"(មាត្រា ២.២)។

២) លទ្ធិប្រជាធិបតេយ្យមិនមែនសមមូលទៅនឹងការបដិសេធនូវនីត្យានុកូលភាពនៃស្ថាប័នដែលស្របតាមរដ្ឋធម្មនុញ្ញ ការបរិហារកេរ្តិ៍ថ្នាក់ដឹកនាំនយោបាយដោយមិនរើសមុខ ការញុះញង់អោយមានកំហឹងជាតិសាសន៍ ការបំពានច្បាប់ ការញុះញង់ជាប្រចាំបង្កភាពតានតឹងនយោបាយ និងកកូរកកាយបង្កបរិយាកាសសង្គ្រាមស៊ីវិលនោះទេ ។

៣) ជាថ្មីម្តងទៀត ដូចនៅក្នុងអំឡុងឆ្នាំ ១៩៧៩-១៩៩១ រដ្ឋាភិបាលលោកខាងលិចមួយចំនួនបានជ្រើសយកការគាំទ្រចំពោះភាគីដែលខុសៈ ពួកគេជ្រើសយកភាគីដែលជម្រុញឲ្យមានភាពអសណ្តាប់ធ្នាប់ ហើយប្រឆាំងទៅនឹងភាគីដែលជម្រុញការអភិវឌ្ឍ ដែលនាំប្រទេសឲ្យរីកចម្រើនក្នុងអត្រាកំណើនផ.ស.ស. ជាមធ្យម ៧,៧% ក្នុងរយៈកាលពីរទសវត្សរ៍ចុងក្រោយ ការកាត់បន្ថយភាពក្រីក្រពី ៥០% នៅឆ្នាំ ១៩៩០ ឲ្យធ្លាក់នៅត្រឹម ១៣,៥% នៅឆ្នាំ ២០១៤ និងភាគីដែលសម្រេចបានស្ទើរតែគ្រប់គោលដៅអភិវឌ្ឍន៍សហវត្សរ៍ ។ ពួកគេជ្រើសយកភាគីដែលបដិសេធអត្ថិភាពនៃរបបប្រល័យពូជសាសន៍ ហើយប្រឆាំងនឹងភាគីដែលបានរំដោះប្រទេស និងការពារប្រជាជនពីការវិលត្រឡប់នៃរបបនេះ ។ ពួកគេជ្រើសយកការគាំទ្រភាគីដែលញុះញង់ឲ្យមានជម្លោះជាមួយវៀតណាម ហើយប្រឆាំងទៅនឹងភាគីដែលផ្តល់តម្លៃជាពិសេសទៅលើសន្តិភាពទាំងនៅក្នុង និងក្រៅប្រទេស ។

៤) រឹតតែអាក្រក់ជាងនេះទៅទៀត មានរដ្ឋាភិបាល និងស្ថាប័នលោកខាងលិចមួយចំនួនដែលបច្ចុប្បន្ននេះនៅតែបន្តគាំទ្របុគ្គលមួយចំនួននៅកម្ពុជាដែលគេស្គាល់ដឹងលឺជាចំហរថា ជាជនរើសអើងពូជសាសន៍ ជាអ្នកដែលបដិសេធ ឬ មិនជឿលើការសម្លាប់រង្គាលដោយរបបខ្មែរក្រហមនៅកម្ពុជា និងអ្នកជាតិនិយមជ្រុល ។ អ្នកនយោបាយប្រជាភិថុតទាំងនេះគឺជាសត្រូវអាក្រក់បំផុតនៃលទ្ធិប្រជា ធិបតេយ្យ ប៉ុន្តែ ពួកគេទទួលបានការគាំទ្រពីប្រទេសលោកខាងលិចមួយចំនួនដែលប្រកាន់លទ្ធិប្រជាធិបតេយ្យ ។

កម្ពុជាត្រូវបានគេជាន់ពន្លិច ពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំ ដោយរបាយការណ៍ពីសារព័ត៌មានដែលមាននិន្នាការប្រឆាំង អង្គការមិនមែនរដ្ឋាភិបាលដែលលំអៀង និងស្ថាប័នដែលបានទទួលព័ត៌មានមិនពិត ដែលបានមូលបង្កាច់តថភាព និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនានា ក្នុងគោលបំណងបង្កើតរូបភាពអវិជ្ជមានចំពោះកម្ពុជា និងដាក់កំហុសទៅលើរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលចង់បង្ហាញពីការពិតជាក់ស្តែងចំពោះបញ្ហារសើបបំផុតមួយចំនួនដូចខាងក្រោម ៖

## ក) អំពីកេរ្តិ៍តំណែលប្រវត្តិសាស្ត្រកន្លងទៅថ្មីៗនេះ

ថ្មីៗនេះ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកស្រី រ៉ូណា ស្មីត (Rhona Smith) បាននិយាយដោយឥតអៀនខ្មាស់ថា "ដល់ពេលវេលាដែលត្រូវឈប់យកស្ថានភាពបច្ចុប្បន្ននេះ ទៅទម្លាក់កំហុសលើបញ្ហាលំបាកកាលពីសតវត្សរ៍មុនហើយ" ។ យើងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលមន្ត្រីសិទ្ធិមនុស្សជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ បានយកភាពឃោរឃៅនៃសង្គ្រាមដែលអាក្រក់ហួសប្រមាណ សេចក្តីវេទនានៃប្រទេសដែលទទួលរងការទម្លាក់គ្រាប់បែកច្រើនជាងគេបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ (គ្រាប់បែកប្រមាណជា ២.៧៥៦.៩៤១តោន ត្រូវបានទម្លាក់មកលើកម្ពុជា ដែលបានសម្លាប់ប្រជាជនស៊ីវិលក្នុងចន្លោះពី ១៥ម៉ឺន ទៅ ៥០ម៉ឺននាក់) ភាពឃោរឃៅនៃសង្គ្រាមដែលប្រើអាវុធគីមីដែលមានរយៈកាល ៩ឆ្នាំ ដែលបានសម្លាប់ប្រជាជនរាប់ពាន់នាក់ បំផ្លាញព្រៃឈើ និងចម្ការកៅស៊ូជាង ១៥ម៉ឺនហិកតា និងការឈឺចាប់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងប្រល័យពូជសាសន៍ មកអធិប្បាយយ៉ាងសាមញ្ញថា ត្រឹមតែជា "បញ្ហាលំបាក" ។

ពិតណាស់ ប្រវត្តិសាស្ត្រក៏ពុំបានអាណិតអាសូរដល់កម្ពុជានោះដែរ ។ ប្រទេសកម្ពុជាមានសន្តិភាពត្រឹមតែពីរទសវត្សរ៍ប៉ុណ្ណោះគឺទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០ ដើម្បីនឹងកសាងអភិវឌ្ឍស្ថាប័នរបស់ខ្លួន។ ប៉ុន្តែ នៅទសវត្សរ៍ឆ្នាំ១៩៧០ បន្ទាប់ពីមានការផ្លាស់ប្តូររបបរៀបចំឡើងដោយរដ្ឋបាលក្រុងវ៉ាស៊ីនតោន កម្ពុជាត្រូវបានទាញធ្លាក់ទៅក្នុងសង្គ្រាម ដែលជ្រកក្រោមស្លាកប្រជាធិបតេយ្យ និងសេរីនិយមបែបលោកខាងលិច ។ប្រទេសកម្ពុជាត្រូវបានគេទម្លាក់គ្រាប់បែកដល់កម្រិតមើលលែងស្គាល់ ដែលរុញឲ្យប្រទេសនេះធ្លាក់ទៅក្នុងដៃនៃរបបប្រល័យពូជសាសន៍ដែលបានសម្លាប់មនុស្សជិតពីរលាននាក់ ។ គ្រប់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គម និងហេដ្ឋារចនាសម្ព័ន្ធរដ្ឋត្រូវបានបំផ្លិចបំផ្លាញ ហើយបញ្ញវន្តដែលជាឆ្អឹងខ្នងនៃស្ថាប័នរដ្ឋត្រូវបានកម្ចាត់ចោលស្ទើរតែគ្មានសល់ ។ ប៉ុន្តែ អ្វីដែលជាពុតត្បុតនោះគឺក្នុងអំឡុងពេលនោះ គ្មានប្រទេសលោកខាងលិចណាមួយធ្លាប់លើកពីឈ្មោះកម្ពុជា ឬក៏និយាយពីបញ្ហាលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនោះទេ កុំថាឡើយដល់ពួកគេមកជួយសង្គ្រោះយើងនោះ ។

បន្ទាប់ពីត្រូវបានរំដោះចេញពីរបបខ្មែរក្រហមនៅឆ្នាំ ១៩៧៩ កម្ពុជាបានខិតខំដើម្បីភាពរស់រានមានជីវិតដោយខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពខ្វះខាតគ្រប់សព្វលើសមត្ថភាពរបស់រដ្ឋ និងស្ថាប័ន ។ជាថ្មីម្តងទៀត កម្ពុជាត្រូវបានគេដាក់ទោសដោយសាររដ្ឋាភិបាលលោកខាងលិចមិនពេញចិត្តអ្នកដែលរំដោះកម្ពុជាធ្វើឲ្យកម្ពុជាបន្តរងគ្រោះដោយការដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងការដាក់ឲ្យកម្ពុជាឯកា រយៈកាល១២ឆ្នាំបន្ទាប់ពីការរំដោះ ។ ការពិតដ៏ឃោរឃៅនេះ វាផ្ទុយស្រឡះពីដោគវាសនារបស់បណ្តាប្រទេសអឺរ៉ុបនៅក្រោយសង្គ្រាមលោកលើកទី ២ ដែលបានទទួលកញ្ចប់ទ្រទ្រង់សេដ្ឋកិច្ច "ផែនការម៉ាស្ហាល" (Marshall Plan) ដ៏ធំមហិមាសម្រាប់ការកសាងប្រទេសឡើងវិញ ។

មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេនៅពេលដែលស្ថាប័នតែមួយដែលតែងតាំងលោកស្រី រ៉ូណា ស្មីត នៅឆ្នាំ ២០១៥ គឺជាស្ថាប័នដែលបដិសេធមិនព្រមអនុម័តលើរបាយការណ៍ អាប់ដែលវ៉ាហាប់ ប៊ូឌីបា (Abdelwahab Bouhdiba Report) ឆ្នាំ ១៩៧៩ ដែលទាញសេចក្តីសន្និដ្ឋានថា "ព្រឹត្តិការណ៍ដែលបានកើតឡើងនៅកម្ពុជាគឺពុំមានឧទាហរណ៍ប្រវត្តិសាស្ត្រណាមួយដែលអាចប្រៀបបាននោះឡើយនៅក្នុងសតវត្សរ៍យើងនេះ ក្រៅតែពីរបបណាហ្ស៊ីដ៏ឃោរឃៅ" ។ ជាលទ្ធផលនៃការបដិសេធនេះ អង្គការសហប្រជាជាតិបានឈានទៅដាក់ទណ្ឌកម្មសេដ្ឋកិច្ចបន្ថែមទៀតមកលើកម្ពុជាពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩១ ហាក់បីដូចជាកម្ពុជារងគ្រោះមិនទាន់គ្រប់គ្រាន់ ដោយហាមឃាត់រាល់ជំនួយអភិវឌ្ឍន៍គ្រប់បែបយ៉ាង ។ ជារួមការបំផ្លិចបំផ្លាញដែលកើតចេញពីការទម្លាក់គ្រាប់បែកខុសច្បាប់ដូចក្រាលព្រំរបស់អាមេរិកមកលើកម្ពុជា ការសម្លាប់ស្ទើរសូន្យនូវធនធានមនុស្សដោយរបប ប៉ុល ពត ការបាក់ស្បាតស្មារតីរបស់អ្នកនៅរស់រានមានជីវិតដែលខិតខំត្រដរបន្តជីវិតនៅក្នុងសង្គមដែលបាក់បែកខ្ទាត់ខ្ទាយ គួបផ្សំនឹងបច្ច័យដ៏ឃោរឃៅដែលកើតចេញពីទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ ទាំងអស់នេះបានបន្សល់ទុកនូវស្នាមរបួសដ៏ជ្រាលជ្រៅដែលនៅមិនទាន់ជាសះ និងផលអាក្រក់មិនអាចគណនាបាននៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ។

សេចក្តីអធិប្បាយដ៏គគ្រើនរបស់លោកស្រី ស្មីត បង្ហាញនូវការប្រមាថដោយឥតលាក់បាំងចំពោះតថភាពដែលកើតមាននៅកម្ពុជា ដែលដូចគ្នានឹងការព្រងើយកន្តើយរបស់មន្ត្រីអន្តរជាតិជាច្រើនផ្សេងទៀតដែលសុខចិត្តជ្រើសយកការវិនិច្ឆ័យ និងថ្កោលទោស ជាជាងខិតខំប្រឹងយល់ និងប្រឹងជួយគាំទ្រ ។

ខ) ស្តីពីគណបក្សនយោបាយ

កម្ពុជាប្រកាន់ខ្ជាប់នូវប្រព័ន្ធប្រជាធិបតេយ្យពហុបក្ស មិនដូចប្រទេសមួយចំនួនដែលមានទំនាក់ទំនងល្អជាមួយលោកខាងលិច ប៉ុន្តែ បែរជាមានប្រព័ន្ធឯកបក្សនោះទេ ។ ភស្តុតាងបានបង្ហាញយ៉ាងច្បាស់ជាក់ស្តែងនូវចំនួនគណបក្សនយោបាយជាច្រើនដែលបានប្រជែងគ្នា ក្នុងពេលបោះឆ្នោតសកល ៥ លើកកន្លងមក៖ នៅឆ្នាំ ១៩៩៣ មាន ២០គណបក្ស នៅឆ្នាំ ១៩៩៨ មាន ៣៩គណបក្ស នៅឆ្នាំ ២០០៣ មាន ២៣គណបក្ស នៅឆ្នាំ ២០០៨ មាន ១១គណបក្ស និងនៅឆ្នាំ ២០១៣ មាន ៨គណបក្ស។

*ច្បាប់ស្តីពីគណបក្សនយោបាយដែលត្រូវបានធ្វើវិសោធនកម្ម៖ មូលហេតុនៃវិសោធនកម្ម*

ច្បាប់ស្តីពីគណបក្សនយោបាយដែលត្រូវបានអនុម័តឆ្នាំ ១៩៩៧ មិនធ្លាប់ត្រូវបានធ្វើវិសោធនកម្ម ២០ឆ្នាំមកហើយ ដែលក្នុងអំឡុងពេលនេះ រដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា បានឆ្លងកាត់ការធ្វើវិសោធនកម្មជាច្រើនលើក។ទន្ទឹមនឹងនេះ ក៏មានច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោតមួយចំនួនត្រូវបានអនុម័ត

ដូចជាច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ល។ ដូច្នេះ មូលហេតុបន្ទាន់ចាំបាច់ក្នុងការធ្វើវិសោធកម្មច្បាប់នេះគឺដើម្បីឆ្លុះបញ្ចាំងការវិវត្តផ្នែកច្បាប់ដែលទាក់ទងនឹងការបោះឆ្នោត ។ ច្បាប់ដែលត្រូវបានធ្វើវិសោធនកម្មនេះត្រូវអនុវត្តដោយមិនរើសអើងចំពោះគ្រប់គណបក្សនយោបាយទាំងអស់ ហើយមានលក្ខខណ្ឌមូលដ្ឋានគ្រប់យ៉ាងដែលសង្គមប្រជាធិបតេយ្យនានាត្រូវតែប្រកាន់ខ្ជាប់ ។ ច្បាប់នេះសំដៅការពារប្រព័ន្ធប្រជាធិបតេយ្យសេរី ពហុបក្ស របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងអធិបតេយ្យភាពរបស់កម្ពុជាពីការលូកលាន់ដោយបរទេសនៅក្នុងការបោះឆ្នោតរបស់ខ្លួន ។ ដោយរៀនសូត្រពីមេរៀនកន្លងមកពីទេសវត្សរ៍ ច្បាប់នេះក៏សំដៅបង្ការការបំភ្លៃគោលការណ៍លទ្ធិប្រជាធិបតេយ្យ ក្រោមលេសលទ្ធិប្រជាធិបតេយ្យ ។

នេះគឺជាកាតព្វកិច្ចដែលមិនអាចបំពានបានរបស់រាជរដ្ឋាភិបាលក្នុងការការពារភាពថ្លៃថ្នូរនៃស្ថាប័នដែលកំពុងមានអត្ថិភាព ។

### *តើអ្វីខ្លះដែលត្រូវបានធ្វើវិសោធនកម្ម?*

ដូចអ្វីដែលប្រទេសប្រជាធិបតេយ្យទាំងអស់ត្រូវធ្វើ ការធ្វើវិសោធនកម្មច្បាប់នេះគឺចាំបាច់ដើម្បីបង្ការការបំពានដែលផ្ទុយនឹងគោលការណ៍មូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ។ ជាឧទាហរណ៍ មាត្រា ៦ ថ្មី ចែងថា គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយដូចតទៅ៖ ១) ធ្វើឲ្យមានអបគមន៍ដែលនាំឲ្យអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី ២)ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ៣) ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ ៤) បង្កើតកងកម្លាំងប្រដាប់អាវុធ ៥) ធ្វើការញុះញង់ដែលអាចនាំឲ្យមានការបែកបាក់ជាតិ ។

មាត្រា ២៩ ថ្មី ចែងថា គណបក្សនយោបាយត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះជាតាមរូបភាពណាក៏ដោយពីស្ថាប័នរដ្ឋ សមាគម អង្គការមិនមែនរដ្ឋាភិបាល សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ វិទ្យាស្ថានសាធារណៈ ។ គណបក្សនយោបាយក៏ត្រូវបានហាមឃាត់មិនឲ្យទទួលវិភាគទាន ទោះតាមរូបភាពណាក៏ដោយពីស្ថាប័នបរទេស ក្រុមហ៊ុនបរទេស ជនបរទេស ឬ អង្គការដែលមានប្រភពហិរញ្ញប្បទានពីបរទេស ។ មាត្រា ៣៤ ថ្មី ចែងថា គណបក្សណាដែលបំពានច្បាប់នេះនឹងត្រូវបានរំលាយដោយតុលាការ ។

## *ការអនុវត្តជាលក្ខណៈអន្តរជាតិទាក់ទងនឹងការហាមឃាត់គណបក្សនយោបាយ*

អ្វីដែលកម្ពុជាបានធ្វើក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយរបស់ខ្លួន គឺមិនខុសប្លែកពីការអនុវត្តជាក់ស្តែងជាលក្ខណៈអន្តរជាតិនោះទេ ។ ចំពោះបញ្ហានេះ តាមរយៈគណៈកម្មាការទីក្រុងវេនីស សហភាពអឺរ៉ុបបានអនុម័ត "គោលការណ៍ស្តីពីការហាមឃាត់ និងការរំលាយគណបក្សនយោបាយ និងវិធានការប្រហាក់ប្រហែល" នៅឆ្នាំ ១៩៩៩ ។ ការហាមឃាត់ ឬ រំលាយគណបក្សនយោបាយអាចធ្វើទៅបានបើសិនជាមានការចាំបាច់ក្នុងការការពារសង្គមប្រជាធិបតេយ្យ ដូចជានៅពេលដែលគណបក្សណាមួយបំផុសបំផុលការប្រើហិង្សាគ្រប់រូបភាព ដូចជា ការរើសអើងពូជសាសន៍ ការស្អប់ខ្ពើមពូជសាសន៍ និងភាពមិនចេះអត់អោន ។

រដ្ឋធម្មនុញ្ញរបស់ដាណឺម៉ាក និងព័ទុយហ្គាល់បានចែងអំពីការហាមឃាត់គណបក្សនយោបាយដែលប្រើប្រាស់ ឬ លើកទឹកចិត្តឲ្យមានអំពើហិង្សា ទោះបីជាគ្មានរូបភាពជាវិទ្ធង្សនា ឬ ប្រកាន់ពូជសាសន៍ក៏ដោយ ។ នៅបារាំង គណបក្សនយោបាយនឹងត្រូវគេហាមឃាត់ ដោយសារការជម្រុញការរើសអើង ការស្អប់ខ្ពើម ឬ ហិង្សាប្រឆាំងទៅនឹងបុគ្គល ឬ ក្រុមបុគ្គលណាមួយ ដោយសារតែដើមកំណើត ឬ ជនជាតិ ឬ សាសនារបស់ពួកគេ ។

នៅឥណ្ឌូណេស៊ី ទង្វើមួយចំនួនត្រូវបានចាត់ទុកថាជា "ឧក្រិដ្ឋកម្មក្នុងការបោះឆ្នោត" ដែលអាចទទួលទោសតាមច្បាប់ ដូចជា ការបរិហារកេរ្តិ៍របស់បុគ្គល សាសនា ជនជាតិ សហគមន៍ បេក្ខជន និង/ឬ អ្នកប្រជែងដទៃទៀតក្នុងការបោះឆ្នោតការញុះញង់ និងបញ្ឆេះជម្លោះរវាងបុគ្គល ឬ សហគមន៍ ការបំពានសណ្តាប់ធ្នាប់សាធារណៈ ការគម្រាមប្រើអំពើហិង្សា ឬ ការញុះញង់ឲ្យប្រើហិង្សាប្រឆាំងនឹងបុគ្គល ឬ ក្រុម និង/ឬ អ្នកប្រជែងដទៃទៀតក្នុងការបោះឆ្នោត ដោយប្រតិបត្តិករ អ្នកចូលរួម និងមន្ត្រីនៃយុទ្ធនាការបោះឆ្នោត ។

នៅម៉ាឡេស៊ី គណបក្សនយោបាយអាចត្រូវបានគេប្រកាសថា ខុសច្បាប់ប្រសិនបើវាត្រូវបានប្រើប្រាស់ក្នុងគោលបំណងដែលប៉ះពាល់ ឬ មិនសមស្របទៅនឹងផលប្រយោជន៍សន្តិសុខ ឬ សណ្តាប់ធ្នាប់សាធារណៈ ឬ សីលធម៌របស់ម៉ាឡេស៊ី ។

នៅហ្វីលីពីន គណៈកម្មាការបោះឆ្នោតអាចបដិសេធការចុះបញ្ជីគណបក្សនយោបាយណាដែលចង់សម្រេចគោលដៅរបស់ខ្លួនតាមរយៈមធ្យោបាយហិង្សា ឬ ខុសច្បាប់ ឬ គណបក្សដែលបដិសេធមិនគោរពរដ្ឋធម្មនុញ្ញ ឬ គណបក្សដែលត្រូវបានគាំទ្រដោយរដ្ឋាភិបាលបរទេស ។

*ការអនុវត្តជាលក្ខណៈអន្តរជាតិទាក់ទងនឹងការហាមឃាត់ការផ្តល់មូលនិធិពីបរទេស*

ទាក់ទងនឹងចំណុចនេះក៏មានឧទាហរណ៍ជាច្រើនស្តីពីការអនុវត្តជាលក្ខណៈអន្តរជាតិ ។ នៅសហរដ្ឋអាមេរិក ច្បាប់ស្តីពីយុទ្ធនាការបោះឆ្នោតសហព័ន្ធចែងថា ជនបរទេសដែលផ្តល់វិភាគទាន ឬ អំណោយជាលុយ ឬ វត្ថុមានតម្លៃផ្សេងទៀត ឬ សន្យាដោយចំហរ ឬ សន្យាដោយតុណ្ហីភាពថានឹងផ្តល់វិភាគទាន ឬ អំណោយ ដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី គឺជាទង្វើខុសច្បាប់ ។ នៅហ្វីលីពីនច្បាប់ទូទៅស្តីពីការបោះឆ្នោតចែងថា ការផ្តល់វិភាគទានហិរញ្ញវត្ថុពីរដ្ឋាភិបាលបរទេស និងភ្នាក់ងាររបស់ពួកគេទៅដល់គណបក្សនយោបាយ អង្គការ សម្ព័ន្ធ ឬ បេក្ខជនដែលទាក់ទងនឹងការបោះឆ្នោតគឺជាការលូកលាន់ក្នុងកិច្ចការជាតិ ហើយនៅពេលដែលមានការទទួលយកវិភាគទានបែបនេះ នឹងផ្តល់ជាមូលដ្ឋានបន្ថែមក្នុងការលុបឈ្មោះចេញពីការចុះបញ្ជីរបស់គណៈកម្មការ បន្ថែមលើការដាក់ទោសផ្សេងទៀតដែលកំណត់ដោយច្បាប់ ។ នៅឥណ្ឌូណេស៊ី ច្បាប់ស្តីពីគណបក្សនយោបាយចែងថា គណបក្សនយោបាយត្រូវបានហាមឃាត់មិនឲ្យទទួលអំណោយពីបុគ្គល ស្ថាប័ន រដ្ឋាភិបាល ឬ អង្គការបរទេស ។ អំណោយពីបរទេសក៏ត្រូវបានហាមឃាត់ផងដែរនៅក្នុងចក្រភពអង់គ្លេស និងសឹង្ហបុរី ។ កាលពីខែ មីនា ឆ្នាំនេះ នៅអូស្ត្រាលី គណៈកម្មាធិការសភាបានលើកជាអនុសាសន៍អំពី "ការហាមឃាត់ការផ្តល់អំណោយពីពលរដ្ឋ និងស្ថាប័នបរទេសទៅដល់គណបក្សនយោបាយដែលមានចុះបញ្ជី" ។

ជាមួយនឹងករណីយុត្តិសាស្ត្រដ៏ច្រើនលើសលុបបែបនេះ រដ្ឋាភិបាល និងស្ថាប័នបរទេសដែលភ្ជាប់ខ្លួនជាមួយនឹងការរិះគន់កម្ពុជាដែលត្រូវបានលើកឡើងដោយកាសែត អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ គួរតែពិនិត្យមើលច្បាប់របស់ខ្លួនឡើងវិញ មុននឹងធ្វើការវិនិច្ឆ័យដោយយោងលើព័ត៌មានលម្អៀង ការប៉ាន់ស្មាន និងការសង្ស័យដែលគ្មានមូលដ្ឋាន ។

## គ. អំពីបញ្ហាដីធ្លី

គឺជាការពិតដែលមានការទទួលស្គាល់ទូលំទូលាយដែលថា ប្រវត្តិសាស្ត្រនយោបាយដ៏រន្ធត់របស់កម្ពុជា មានបច្ច័យគួរឲ្យកត់សម្គាល់ទៅលើច្បាប់ភូមិបាល និងស្ថាប័នរបស់កម្ពុជា។ កម្មសិទ្ធិដីឯកជនត្រូវបានលុបបំបាត់ចោលក្នុងរបបខ្មែរក្រហម ហើយបញ្ហាដីធ្លីជាច្រើននាពេលបច្ចុប្បន្ន គឺជាប់ពាក់ព័ន្ធទៅនឹងការខិតខំប្រឹងប្រែងបង្កើតឡើងវិញនូវសិទ្ធិធ្វើជាម្ចាស់លើដីឯកជននោះឯង ។ អស់រយៈពេលជាងមួយទសវត្សរ៍បន្ទាប់ពីការរំដោះ ការកាន់កាប់ដីធ្លីពុំមានការគ្រប់គ្រងទាល់តែសោះ ដោយសារតែការខ្វះខាតយ៉ាងខ្លាំងនូវធនធានមនុស្ស និងបច្ច័យដែលកើតចេញពីទណ្ឌកម្មរបស់បស្ចិមប្រទេស។ បន្ទាប់ពីចំណាយពេលជាច្រើនឆ្នាំដើម្បីរៀបចំសេចក្តីព្រាង និងការកែប្រែអត្ថបទច្បាប់រួចមក ច្បាប់ភូមិបាលបច្ចុប្បន្នត្រូវបានអនុ

ម័តនៅឆ្នាំ២០០១ និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាបានផ្តល់នូវមូលដ្ឋានគតិយុត្តិដ៏ល្អសម្រាប់គ្រប់គ្រងដីធ្លី បើទោះបីជានៅតែមានតម្រូវការបន្ថែមនូវអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀតដើម្បីកែលម្អការអនុវត្តជាក់ស្តែងក៏ដោយ ។

រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងពេញទំហឹង ក្នុងការដោះស្រាយការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជារួម ។ គិតត្រឹមខែកញ្ញា ឆ្នាំ២០១៦ ប័ណ្ណកម្មសិទ្ធិដីចំនួន ៤,៣លាន ត្រូវបានទទួលស្គាល់ជាផ្លូវការ ពោលគឺស្មើនឹង ៦១% នៃក្បាលដីដែលមានស្រាប់ប្រមាណជា ៧លាន។ រាជរដ្ឋាភិបាលបានកំណត់គោលដៅយ៉ាងមុតមាំដើម្បីបញ្ចប់ដំណើរការចុះបញ្ជីដីធ្លីឲ្យបានចប់សព្វគ្រប់នៅត្រឹមឆ្នាំ២០២៣។

បើទោះបីជាមានសមិទ្ធផលវិជ្ជមានទាំងនេះក៏ដោយ ក៏បញ្ហាដីធ្លីនៅក្នុងទីតាំងមួយចំនួនក្នុងប្រទេសត្រូវបានគេបង្កជារឿងនយោបាយដោយអយុត្តិធម៌។ ការជ្រៀតជ្រែកដោយខុសច្បាប់ និងដោយគគ្លើនរបស់គណបក្សនយោបាយជាមួយនឹងស្ទើរតែរាល់គ្រប់បញ្ហារបស់ប្រជាជនគ្រប់ស្រទាបវណ្ណៈដោយមិនខ្វល់ពីនីតិវិធីច្បាប់ និងយន្តការដោះស្រាយជម្លោះដែលមានស្រាប់ បានបង្កឲ្យមានភាពស្មុគស្មាញ និងធ្វើឲ្យបញ្ហាទៅជាមានលក្ខណៈអណោចអធមទៅវិញ ។ គណបក្សនយោបាយមួយចំនួនបានប្រើប្រាស់បញ្ហាដីធ្លីបច្ចុប្បន្នដោយឥតអៀនខ្មាស់ដើម្បីកេងចំណេញនយោបាយផ្ទាល់ខ្លួន តាមរយៈការសាបព្រោះកំហឹង និងធ្វើឲ្យបាត់បង់ទំនុកចិត្តពីក្នុងចំណោមប្រជាជន។

វាជាការចាំបាច់ ដែលបញ្ហាដែលមានលក្ខណៈបច្ចេកទេស និងដ៏រសើបបែបនេះត្រូវបានដោះស្រាយតាមរយៈមធ្យោបាយបច្ចេកទេសនិងគតិយុត្តិជាជាងតាមរយៈការធ្វើឲ្យក្លាយទៅជារឿងនយោបាយសុទ្ធសាធ ។

### ឃ. អំពីបញ្ហា "ប្រព័ន្ធតុលាការជាឧបករណ៍នយោបាយ?"

ការចោទប្រកាន់ប្រឆាំងនឹងសកម្មជនសិទ្ធិមនុស្ស និងតំណាងរាស្ត្រគណបក្សប្រឆាំងគួរត្រូវបានពិចារណាដោយប្រើទស្សនៈផ្លូវច្បាប់។ ជនទាំង ២៦រូប ដែលត្រូវបានគេហៅថាជា"អ្នកទោសនយោបាយ" ពុំមែនត្រូវបានដាក់ពន្ធនាគារដោយសារតែហេតុផលនយោបាយនោះទេ ប៉ុន្តែគឺដោយសារតែការរំលោភច្បាប់ ។ សកម្មជននយោបាយ និងសិទ្ធិមនុស្ស មិនមែនស្ថិតនៅពីលើច្បាប់នោះទេ ។

ទាក់ទងនឹងរឿងក្តីរបស់តំណាងរាស្ត្រវិញ វានឹងក្លាយជារឿងដែលមិនធ្លាប់មានពីមុនមកប្រសិនបើតំណាងរាស្ត្រត្រូវបានគេអនុញ្ញាតឲ្យប្រើប្រាស់ផែនទី និងសន្និសញ្ញាព្រំដែនក្លែងក្លាយដើម្បីទទួលបានការគាំទ្រនយោបាយ តាមរយៈការបង្កឲ្យមានការស្អប់ខ្ពើមជាតិសាសន៍ និងការញុះញង់ប្រឆាំងនឹងប្រទេសជិតខាង ។ បើនិយាយប្រៀបធៀប គឺវាមានលក្ខណៈស្រដៀងគ្នានឹងការណ៍ដែលសមាជិកសភាសហភាពអឺរ៉ុបណាម្នាក់យកផែនទីក្លែងក្លាយរវាងបារាំង និងអាល្លឺម៉ង់ ឬ រវាងអាល្លឺម៉ង់ និងប៉ូឡូញនៅក្រោយ

សង្គ្រាមលោកលើកទីពីរមកបង្ហាញ ឬ ក៏សមាជិកសភាណាមួយលើកយកទ្រឹស្តីណាហ្ស៊ីមកឃោសនានៅក្នុងសភារបស់សហភាពអឺរ៉ុបអញ្ចឹង។ដូចគ្នានេះដែរ យើងអាចស្រមៃទៅដល់ករណីដែលមានតំណាងរាស្ត្រនៃប្រទេសជាសមាជិកអាស៊ានណាមួយ បង្ហាញផែនទីក្លែងក្លាយរវាងម៉ាឡេស៊ី និងថៃ ឬរវាងម៉ាឡេស៊ី និងឥណ្ឌូណេស៊ី។

ពាក់ព័ន្ធនឹងរឿងក្តីរបស់សកម្មជនសិទ្ធិមនុស្ស និងមន្ត្រីអង្គការសហប្រជាជាតិ មានការយល់ឃើញដោយចំហរថា អង្គការមិនមែនរដ្ឋាភិបាល (NGO) និងបុគ្គលិកអង្គការសហប្រជាជាតិ គប្បីជម្រុញ និងបណ្តុះបណ្តាលប្រជាជនឲ្យគោរពច្បាប់ មិនមែនឲ្យបំពានច្បាប់នោះឡើយ។ មន្ត្រីសមាគមអាដហុក ៤រូប និងអគ្គលេខាធិការរង ១រូប នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានចោទប្រកាន់ដោយអនុលោមតាមច្បាប់ជាក់លាក់យោងតាមមាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌពីបទញុះញង់ឲ្យសាក្សីផ្តល់សក្ខីកម្មភូតកុហកពោលគឺមិនមែនជាការកាត់សេចក្តីតាមអំពើចិត្តនោះឡើយ។

បទប្បញ្ញត្តិដូចគ្នានេះក៏ត្រូវបានអនុវត្តចំពោះបុគ្គលិកនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR)ប្រចាំនៅក្រុងភ្នំពេញ ដែលត្រូវបានការពារដោយអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិផងដែរ។ បុគ្គលិករូបនេះបានព្យាយាមបញ្ចុះបញ្ចូលសាក្សីឲ្យផ្តល់សក្ខីកម្មក្លែងក្លាយ ដោយធានាថា អង្គការរបស់គាត់នឹងផ្តល់សិទ្ធិជ្រកកោនទៅឲ្យសាក្សី និងក្រុមគ្រួសាររបស់នាងនៅឯបរទេស ។ អាជ្ញាធរកម្ពុជាមានភស្តុតាងយ៉ាងរឹងមាំនៅលើករណីនេះ ។ អ្វីដែលគួរឲ្យហួសចិត្តនោះគឺវាមិនមែនជាលើកទីមួយទេ ដែលបុគ្គលិកអង្គការសហប្រជាជាតិមកពីការិយាល័យសិទ្ធិមនុស្ស OHCHR មានពាក់ព័ន្ធនឹងទង្វើឧក្រិដ្ឋបែបនេះ ។ ករណីដ៏ជាក់លាក់មួយគឺពាក់ព័ន្ធនឹងលោក គ្រីស្តូហ្វី ប៉េសស៊ូ (Christopher Peschoux) អតីតតំណាងការិយាល័យសិទ្ធិមនុស្សOHCHR ដែលបានប៉ុនប៉ងបញ្ចុះបញ្ចូលលោក កាំង ហ្គេចអ៊ាវ ហៅឌុច ដែលជាអតីតប្រធានគុកទួលស្លែងដែលមានកេរ្តិ៍ឈ្មោះអសោចរបស់ខ្មែរក្រហម (មន្ទីរស២១) ឲ្យភៀសខ្លួនទៅក្រៅប្រទេសមុនពេលដែលអាជ្ញាធរកម្ពុជាចាប់ខ្លួន។

យោងតាមក្រមប្រតិបត្តិសម្រាប់មន្ត្រីស៊ីវិលអន្តរជាតិឆ្នាំ ២០១៣មន្ត្រីស៊ីវិលអន្តរជាតិមិនត្រូវលម្អៀង និងត្រូវគោរពគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង និងអធិបតេយ្យភាពនៃរដ្ឋជាម្ចាស់ផ្ទះ ។ ប៉ុន្តែ ករណីទាំងពីរខាងលើ បង្ហាញយ៉ាងច្បាស់ពីការរំលោភក្រមសីលធម៌យ៉ាងធ្ងន់ធ្ងរដោយមន្ត្រីស៊ីវិលអន្តរជាតិមួយចំនួន ។ ជាជាងការអនុវត្តកាតព្វកិច្ចរបស់ពួកគេក្នុងការរក្សាទំនាក់ទំនងឲ្យបានល្អបំផុតជាមួយរដ្ឋម្ចាស់ផ្ទះ ពួកគេបែរជាប្រព្រឹត្តឥរិយាបថដែលមិនសក្តិសមជាមន្ត្រីស៊ីវិលអន្តរជាតិ ដូចជាការបង្ខូចកេរ្តិ៍ឈ្មោះ ការធ្វើឲ្យអន្តរាយ ឬ ការប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាលទៅវិញ ។

*វាក្យខ័ណ្ឌ ៣៣ ៖ "វាគឺជាកាតព្វកិច្ចដ៏ច្បាស់លាស់មួយដែលមន្ត្រីស៊ីវិលអន្តរជាតិទាំងអស់ត្រូវរក្សាទំនាក់ទំនងឲ្យបានល្អបំផុតជាមួយនឹងរដ្ឋាភិបាល និងចៀសវាងសកម្មភាពណាមួយដែលអាចធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងនេះ ។ គេមិនត្រូវជ្រៀតជ្រែកក្នុងគោលនយោបាយ ឬ កិច្ចការ*

*របស់រដ្ឋាភិបាលឡើយ ។ វាជាការមិនអាចទទួលយកបានឡើយ ទោះបីជាលក្ខណៈបុគ្គល ឬ ជាសមូហភាពដែលពួកគេធ្វើការរិះគន់ ឬ ព្យាយាមបង្ខូចកេរ្តិ៍ឈ្មោះរដ្ឋាភិបាលណាមួយ ។ ... សកម្មភាពណាមួយ ទោះបីដោយផ្ទាល់ ឬ ដោយប្រយោលដើម្បីធ្វើឲ្យអន្តរាយ ឬ ផ្តួលរំលំរដ្ឋាភិបាលគឺជាកំហុសដ៏ធ្ងន់ធ្ងរ" ។*

ខណៈដែលមន្ត្រីស៊ីវិលអន្តរជាតិមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិជាក់លាក់មួយចំនួន ពួកគេក៏មានកាតព្វកិច្ចត្រូវគោរពច្បាប់ក្នុងស្រុកផងដែរ ៖

*វាក្យខ័ណ្ឌ ៤៣៖ "បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលមន្ត្រីស៊ីវិលអន្តរជាតិមាន គឺត្រូវបានផ្តល់ជូនឲ្យពួកគេតែនៅក្នុងផលប្រយោជន៍របស់អង្គការតែប៉ុណ្ណោះ ។ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងនេះ មិនបានលើកលែងមន្ត្រីស៊ីវិលអន្តរជាតិចេញពីការគោរពច្បាប់ក្នុងស្រុក ឬក៏ផ្តល់ឲ្យពួកគេនូវលេសក្នុងការមិនអើពើចំពោះកាតព្វកិច្ចផ្លូវច្បាប់ ឬហិរញ្ញវត្ថុឯកជននោះឡើយ។ ..."*

ទាក់ទងទៅនឹងទំនាក់ទំនងរបស់ពួកគេជាមួយគណបក្សនយោបាយ មន្ត្រីស៊ីវិលអន្តរជាតិមិនត្រូវលម្អៀងទេ ហើយពួកគេក៏មិនត្រូវគាំទ្រគណបក្សនយោបាយណាមួយ បើទោះបីជាស្ថិតក្រោមទម្រង់ណាមួយក៏ដោយ៖

*វាក្យខ័ណ្ឌ ៤៨៖ "ផ្អែកលើភាពឯករាជ្យ និងភាពមិនលម្អៀងដែលមន្ត្រីត្រូវតែរក្សាខ្ជាប់ខ្ជួន មន្ត្រីស៊ីវិលអន្តរជាតិ ទោះបីជានៅរក្សាសិទ្ធិបោះឆ្នោតក៏ដោយ ក៏មិនត្រូវចូលរួមក្នុងសកម្មភាពនយោបាយដូចជា ការឈរឈ្មោះ ឬក៏កាន់តំណែងនយោបាយក្នុងថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិឡើយ។ ... វាគឺជាការចាំបាច់ដែលមន្ត្រីស៊ីវិលអន្តរជាតិត្រូវចៀសវាងក្នុងការគាំទ្រចំពោះគណបក្ស ឬ យុទ្ធនាការនយោបាយ ហើយពួកគេមិនត្រូវទទួលយក ឬ អង្គាសមូលនិធិ សរសេរអត្ថបទ ឬ ធ្វើសុន្ទរកថាជាសាធារណៈ ឬ ចេញសេចក្តីថ្លែងការណ៍ទៅកាន់សារព័ត៌មានឡើយ"។*

កាលពីឆ្នាំមុន លោកស្រី វ៉ាន់ ហៀលី (Wan-Hea Lee)តំណាងការិយាល័យ OHCHR បានធ្វើការអត្ថាធិប្បាយលើសេចក្តីសម្រេចមួយដែលហាមឃាត់លោក សម រង្ស៊ី មិនឲ្យវិលចូលកម្ពុជាថា ជារឿង "មិនសមហេតុផល និងធ្វើតាមអំពើចិត្ត" ។ "ការសម្រេចចិត្តនេះចាំបាច់ត្រូវមានការពន្យល់ជាបន្ទាន់បើទោះបីជាមានឱកាសស្តួចស្តើងដែលការពន្យល់ណាមួយ នឹងត្រូវបានទទួលយកដោយគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ឬក៏គេត្រូវផ្លាស់ប្តូរការសម្រេចចិត្តនេះ" ។ លោកស្រីបានបញ្ចេញទស្សនៈផ្ទាល់ខ្លួនរួចទៅហើយនៅមុនពេលទទួលបានសេចក្តីពន្យល់ ។ សេចក្តីថ្លែងការណ៍របស់លោកស្រីត្រូវបានចាត់ទុកថាលម្អៀងទាំងស្រុងប្រឆាំងនឹងរដ្ឋាភិបាល និងជាការរំលោភយ៉ាងច្បាស់ក្រឡែតទៅលើក្រមប្រតិបត្តិដែលត្រូវបានដកស្រង់ខាងលើនេះ។

## ង. អំពីសេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា

គេតែងតែរាយការណ៍ថា សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជាកំពុងស្ថិតនៅក្រោមការគម្រាមកំហែង ។

បច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជាមានរោងពុម្ពផ្សាយព័ត៌មានចំនួនជាង ៨០០ សារព័ត៌មានតាមអ៊ីនធើនែតចំនួន ៧០ ស្ថានីយទូរទស្សន៍ ២២ ស្ថានីយវិទ្យុ ៣៣០ និងសមាគមអ្នកកាសែត ៣៨សមាគម ។

រាជរដ្ឋាភិបាលមានការប្ដេជ្ញាចិត្តក្នុងការបង្កើនការប្រើប្រាស់អ៊ីនធើនែតនៅទូទាំងប្រទេស ហើយសព្វថ្ងៃនេះ ប្រជាជនប្រមាណជា ៥០% អាចប្រើអ៊ីនធើនែតបាន ។ បើរាជរដ្ឋាភិបាលចង់ដាក់កម្រិតសេរីភាពនៃការបញ្ចេញមតិដូចគេថាមែននោះ ម្ល៉េះមិនចាំបាច់ខិតខំបង្កើនបណ្ដាញដែលល្អបំផុតសម្រាប់ការចែករំលែកព័ត៌មាន និងមតិយោបល់ដោយសេរីដូចសព្វថ្ងៃនោះទេ ។

ការបោះពុម្ពផ្សាយកាសែតគឺមានលក្ខណៈសេរីខ្លាំងណាស់ រហូតដល់កាសែតខាំបូឌាដេលី និងកាសែតភ្នំពេញប៉ុស្តិ៍ដែលជាកាសែតភាសាអង់គ្លេសដ៏ធំ និងមានបកប្រែជាភាសាខ្មែរ បានបោះពុម្ពផ្សាយជាប្រចាំថ្ងៃនូវការរិះគន់ខ្លាំងៗ ព្រមទាំងមានការចោទប្រកាន់ដោយគ្មានមូលដ្ឋានប្រឆាំងនឹងរាជរដ្ឋាភិបាលដោយផ្អែកលើការសង្ស័យសុទ្ធសាធ។ អត្ថបទរបស់ពួកគេពោរពេញទៅដោយការចោទប្រកាន់ ដោយផ្អែកលើការប៉ាន់ស្មាន ជាមួយនឹងការប្រើពាក្យពេចន៍ដូចជា "គេមើលឃើញជាទូទៅថា..." "មានលទ្ធភាពខ្ពស់ដែលថា..." "វាអាចទៅរួចដែលថា..." ។ល។

ខណៈដែលរាជរដ្ឋាភិបាលមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការប្ដឹងទៅតុលាការចំពោះការចុះផ្សាយអត្ថបទរបស់កាសែតទាំងពីរនេះ រាជរដ្ឋាភិបាលបានចៀសវាងមិនធ្វើចំណាត់ការផ្លូវច្បាប់ប្រឆាំងនឹងពួកគេ ។ ជាការពិត នាយកកាសែតខាំបូឌាដេលី បានសារភាពដោយខ្លួនឯងថា កាសែតរបស់លោកគឺ "មានភាពសេរីជាងកាសែត ញូវយ៉កថាម (New York Times)នៅទីក្រុងញូវយ៉ក និងកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ (Washington Post)នៅទីក្រុងវ៉ាស៊ីនតោនទៅទៀត" ។

វិទ្យុសំឡេងសហរដ្ឋអាមេរិក(VOA) និងវិទ្យុអាស៊ីសេរី ដែលជាស្ថានីយវិទ្យុគាំទ្រគណបក្សប្រឆាំងដោយផ្ទាល់មុខ និងដែលមានកម្មវិធីជាភាសាខ្មែរយ៉ាងវែង ត្រូវបានចាក់ផ្សាយនៅទូទាំងប្រទេសដោយគ្មានការត្រួតពិនិត្យ ឬ ការដាក់កម្រិតណាមួយពីរាជរដ្ឋាភិបាលឡើយ ។

ប្រព័ន្ធផ្សព្វផ្សាយដែលលម្អៀងទាំងនេះត្រូវបានផ្ដល់សេរីភាពក្នុងការធ្វើប្រតិបត្តិការរបស់ខ្លួន បើទោះបីមានរបៀបវារៈលាក់កំបាំងដើម្បីបំផ្លាញរូបភាព និងកេរ្តិ៍ឈ្មោះរបស់រាជរដ្ឋាភិបាលក៏ដោយ ។

កាសែតប្រឆាំងជាភាសាខ្មែរក៏មានដែរ ។ទាក់ទិននឹងបញ្ហាសារព័ត៌មាន រាជរដ្ឋាភិបាលបានបញ្ជាក់យ៉ាងច្បាស់ថា សេរីភាពនៃការបញ្ចេញមតិគឺមិនមែនមានន័យថាជាសេរីភាពពេញលេញក្នុងការជេរប្រមាថ ឬបញ្ចេញព័ត៌មានក្លែងក្លាយ ឬបង្ខូចកេរ្តិ៍ឈ្មោះបុគ្គលនោះឡើយ។ នៅក្នុងបស្ចិមប្រទេសទាំងអស់ក៏មាន

ច្បាប់ដាក់ទោសទៅលើការប្រព្រឹត្តបែបនេះដែរ។ ហេតុអ្វីបែរជាត្រូវមានករណីលើកលែងនៅប្រទេសកម្ពុជាទៅវិញ ?

បើយោងតាមសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០១៦ របស់ "អ្នករាយការណ៍គ្មានព្រំដែន" (RSF) កម្ពុជាជាប់ចំណាត់ថ្នាក់ទីមួយក្នុងចំណោមបណ្តាប្រទេសអាស៊ានទាំងដប់ ។

## ច. អំពីច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល (NGO)

កម្ពុជាមានសមាគម និង NGO ជាតិ និងអន្តរជាតិ ដែលបានចុះបញ្ជីចំនួន ៦.២៦៨ស្ថាប័ន។ NGO ក្នុងស្រុកមួយចំនួនបានតាំងខ្លួនជាតំណាងឲ្យ "សង្គមស៊ីវិល"និងអួតអាងថា និយាយក្នុងនាម ប្រជាជនទាំងមូល បើទោះបីជាគ្មានភាពស្របច្បាប់ណាមួយក្នុងការធ្វើដូច្នេះ សូម្បីតែបន្តិចក៏ដោយ ។ NGO បែបនេះមួយចំនួន លាក់ខ្លួននៅពីក្រោយវាំងនននៃសកម្មភាពអភិវឌ្ឍន៍ ឬ មនុស្សធម៌ ដែលតាមការពិតពួកគេបានចូលរួមពាក់ព័ន្ធយ៉ាងជ្រាលជ្រៅនៅក្នុងសកម្មភាពនយោបាយ ដែលត្រូវបានផ្តល់មូលនិធិដោយស្ថាប័ន និងរដ្ឋាភិបាលបរទេស ។

ដោយសារតែបញ្ហាខ្វះខាតតម្លាភាព និងគណនេយ្យភាពនៅក្នុង NGO ទាំងនេះហើយ ទើបរដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់ស្តីពី NGO នៅឆ្នាំ២០១៦។ តាមប្រវត្តិ សេចក្តីព្រាងច្បាប់ជាលើកដំបូងត្រូវបានស្នើឡើងចំពោះសហគមន៍ NGO កាលពីឆ្នាំ ១៩៩៦ ពោលគឺបន្ទាប់ពីមានការមកដល់នៃ NGO រាប់រយក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ ដូច្នេះ គេអាចនិយាយដោយមិនអាចប្រកែកបានថា ច្បាប់ NGO គឺជាលទ្ធផលនៃការជជែកវែកញែក និងការពិភាក្សាជាមួយសង្គមស៊ីវិល និងស្ថានទូតបរទេសអស់រយៈពេលជាង ២០ឆ្នាំមកហើយ។ តើយើងត្រូវធ្វើកិច្ចពិគ្រោះយោបល់ច្រើនប៉ុណ្ណាទៀតទៅ ?

ច្បាប់នេះត្រូវបានបង្កើតឡើងយ៉ាងប្រុងប្រយ័ត្ន ដោយប្រមែប្រមូលបទពិសោធន៍ល្អៗនៅក្នុងច្បាប់ NGO របស់បណ្តាប្រទេសប្រជាធិបតេយ្យដែលមានភាពចាស់ទុំផ្សេងទៀតដូចជា បារាំង អូស្ត្រាលី សិង្ហបុរី ថៃ ជប៉ុន អាមេរិក (រដ្ឋញូវយ៉ក និងរដ្ឋកាលីហ្វ័រញ៉ា)។ បទប្បញ្ញត្តិទាំងឡាយនេះក៏មានខ្លឹមសារស្របទៅនឹងអនុស្សារណៈនៃការយោគយល់គ្នាដែល NGO បរទេសជាង ៤០០ បានចុះហត្ថលេខារួចរាល់ហើយជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ជារឿងដែលមិនសមហេតុផលទាល់តែសោះ ដែលសេចក្តីព្រាងចុងក្រោយដែលត្រូវបានព្រាងក្រោមការសហការយ៉ាងជិតស្និទ្ធជាមួយអ្នកការទូតបរទេស បែរជាត្រូវបានប្រានចោលដោយស្ថានទូតអាមេរិក និង NGO មួយចំនួនដែលទទួលការណែនាំ និងផ្តល់មូលនិធិដោយស្ថានទូតអាមេរិក។ ឥឡូវនេះច្បាប់នេះបានលេចចេញជារូបរាងហើយ ។ ហេតុអ្វីបានជាគេបដិសេធសិទ្ធិរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុង

ការមានច្បាប់ផ្ទាល់ខ្លួនស្តីពីសមាគម ហើយដែលការបដិសេធនេះធ្វើដោយតំណាងនៃប្រទេសមួយដែលមានលក្ខខណ្ឌចុះបញ្ជីស្រដៀងគ្នាសម្រាប់ NGO ជាតិ និងអន្តរជាតិទៅវិញ ?

ច្បាប់នេះបានបញ្ចប់ស្ថានភាពរីករវមួយដែលបង្កើតឡើងដោយសកម្មភាពរបស់NGO ដែលធ្វើការនៅក្នុងចន្លោះប្រហោងនៃច្បាប់។ទោះជាយ៉ាងណាច្បាប់NGO របស់កម្ពុជាមិនមានការគម្រាមកំហែងខ្លាំងចំពោះប្រជាធិបតេយ្យទេបើយើងធៀបទៅនឹងផលប៉ះពាល់នៃ "ច្បាប់ស្នេហាជាតិ"(Patriot Act) ឬ "ច្បាប់ការពារជាតិ"(National Defense Authorization Act)របស់អាមេរិកឬច្បាប់ "C-51" របស់កាណាដានោះ។

លើសពីនេះទៀត ច្បាប់នេះមានលក្ខណៈស្របគ្នាទៅនឹងក្របខ័ណ្ឌគតិយុត្តិអន្តរជាតិដែលមានស្រាប់ដូចជា៖ មាត្រា ៤២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាដែលជានាថា សិទ្ធិរបស់សមាគមត្រូវបានគ្រប់គ្រងដោយច្បាប់; មាត្រា ២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស; និងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។

NGO ជាតិ និងអន្តរជាតិ ដែលប្រដាប់ដោយរបៀបវារៈនយោបាយបង្កប់ បានប្រើប្រាស់ព្រមទាំងបន្តក្រឡៃបទប្បញ្ញត្តិជាក់លាក់មួយចំនួននៃច្បាប់នេះ និងធ្វើការប៉ាន់ស្មានដោយងងឹតងងុលគ្មានអង្គហេតុច្បាស់លាស់។ ជារឿងអកុសល ការពិតដ៏គួរឲ្យសោកស្តាយមួយនោះគឺអ្នកកាសែត និងមន្ត្រីការទូតបរទេសភាគច្រើនបំផុតតែងតែទទួលយកជាទូទៅនូវអ្វីក៏ដោយដែលមានប្រភពចេញមកពី NGO ដោយចាត់ទុកថាជាសេចក្តីពិតដាច់ខាត។ ទំនាក់ទំនងរវាង NGO ដែលលម្អៀង និងដែលទទួលបានមូលនិធិពីរដ្ឋាភិបាលបរទេស ជាមួយនឹងអ្នកកាសែត និងមន្ត្រីការទូតបស្ចិមប្រទេសមួយចំនួនដែលមានរបៀបវារៈស្រាប់ បានផ្តល់នូវតម្រុយយ៉ាងច្បាស់ចំពោះសំណួរថា ហេតុអ្វីបានជាមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំង និងស៊ីចង្វាក់គ្នាបែបនេះ នៅក្នុងការធ្វើឲ្យអន្តរាយដល់អាជ្ញាធរកម្ពុជា។

## ឆ. អំពីគណបក្សប្រឆាំង

ក) លោកសមរង្ស៊ីដែលស្ទាត់ជំនាញទាំងភាសាអង់គ្លេសនិងភាសាបារាំងនិយាយបានយ៉ាងល្អអំពីប្រជាធិបតេយ្យនិងសិទ្ធិមនុស្សទៅកាន់ទស្សនិកជនបស្ចិមប្រទេស ។ប៉ុន្តែ គាត់មិនបាននិយាយបែបនេះទេនៅពេលដែលគាត់និយាយជាភាសាខ្មែរ ។គាត់ប្រើប្រាស់វាក្យសព្ទផ្សេងគ្នាសម្រាប់ក្រុមមនុស្សខុសគ្នា ។គាត់និយាយដូចគ្នានឹងអ្នកប្រជាភិថុតនៅបស្ចិមប្រទេសដែរហើយលោកគឺជាបេក្ខជនតែមួយគត់ដែលអង្គការសហប្រជាជាតិបានស្តីបន្ទោសចំពោះសេចក្តីថ្លែងការណ៍រើសអើងជាតិសាសន៍ក្នុងអំឡុងការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិកាលពីឆ្នាំ ១៩៩៣ ។គាត់មានកេរ្តិ៍ឈ្មោះអសោចខាងប្រើសេចក្តីថ្លែងការណ៍និងវោហាសាសន៍ជាភាសាខ្មែរដែលពោរពេញទៅដោយការញុះញង់និងការស្អប់

ខ្ពើមជាតិសាសន៍។ ជាថ្មីម្តងទៀត គាត់ត្រូវបានគេចោទរឿងបញ្ឆេះកំហឹងរើសអើងជាតិសាសន៍ នៅក្នុងយុទ្ធនាការបោះឆ្នោតឆ្នាំ ១៩៩៨ ដោយប្រើប្រាស់វោហាសាសន៍ប្រឆាំងវៀតណាមយ៉ាងខ្លាំងក្លា ហើយក្រុមបាតុករដែលពេញដោយកំហឹង បានវាយប្រហារ និងដុតស្តូបមិត្តភាពកម្ពុជា វៀតណាម មុនពេលដែលគាត់អាចទប់កំហឹងរបស់ពួកគេបាន ។ មួយសប្តាហ៍ក្រោយព្រឹត្តិការណ៍នេះ ការវាយប្រហារដោយហ្វូងមនុស្សដែលពេញដោយកំហឹងបានសម្លាប់ជនជាតិវៀតណាមយ៉ាងតិច ៤រូប ដែលជាការសម្លាប់ដោយសារការរើសអើងពូជសាសន៍ ។ គាត់ក៏មានឈ្មោះបោះសម្លេងផងដែរទាំងនៅក្នុងប្រទេសបារាំងនិងប្រទេសកម្ពុជាដោយសារការបរិហាកេរ្តិ៍សមាជិករដ្ឋាភិបាលម្នាក់ហើយករណីបរិហារកេរ្តិ៍នេះ ត្រូវបានទទួលស្គាល់ដោយតុលាការបីលើកជាប់ៗគ្នា បូករួមទាំងតុលាការនៅប្រទេសបារាំង ។

លោកក៏ធ្លាប់ញុះញង់ឲ្យប្រជាជនសាមញ្ញដកបង្គោលតម្រុយព្រំដែនអន្តរជាតិ ដែលនេះគឺជាទង្វើមួយមិនអាចអត់ឱនឲ្យបានឡើយហើយរដ្ឋាភិបាលបស្ចិមប្រទេសណាក៏ដោយ ក៏ប្រាកដជាថ្កោលទោសទង្វើបែបនេះដូចគ្នា ។ មនុស្សគ្រប់គ្នានៅកម្ពុជាគឺសុទ្ធតែដឹងយ៉ាងច្បាស់ថាបញ្ហាព្រំដែនជាមួយវៀតណាមគឺជាបញ្ហាដ៏រសើបណាស់ដែលជានិច្ចកាលនាំទៅរកភាពតានតឹង និងអសណ្តាប់ធ្នាប់សាធារណៈ លើកលែងតែអ្នកកាសែតមួយចំនួនដែលមានចេតនាអាក្រក់ប៉ុណ្ណោះ ។

ការប្រឡែងលេងជាមួយនឹងបញ្ហាវៀតណាមដើម្បីចំណេញសំឡេងឆ្នោតគឺជាកង្វះការទទួលខុសត្រូវដ៏សែនគ្រោះថ្នាក់ហើយទង្វើបែបនេះមិនត្រូវបានគេអត់ឱនឲ្យបានឡើយ។

ខ) លោកកឹមសុខាមានជាប់ពាក់ព័ន្ធនឹងរឿងក្តីនៃការញ៉ាំងឲ្យសាក្សីផ្តល់សក្ខីកម្មភូតកុហក ដែលជាបទឧក្រិដ្ឋមួយទទួលស្គាល់ដោយប្រទេសប្រជាធិបតេយ្យទាំងអស់ ។ ការបដិសេធមិនបង្ហាញខ្លួននៅក្នុងតុលាការតាមការកោះហៅរបស់ព្រះរាជអាជ្ញាគឺត្រូវផ្តន្ទាទោសនៅក្នុងប្រទេសប្រជាធិបតេយ្យទាំងអស់។ ប្រទេសកម្ពុជាប្រកាន់ខ្ជាប់នូវគោលការណ៍នីតិរដ្ឋដូចគ្នា។ ព័ត៌មានក្លែងក្លាយដែលផ្សព្វផ្សាយដោយប្រភពលម្អៀងនៅកម្ពុជាបានបង្កើតការភ័ន្តច្រឡំរវាង "សាក្សី"និង "ជនជាប់ចោទ" ។ លោកកឹមសុខាត្រូវបានកោះហៅក្នុងនាមជាសាក្សីចំនួនពីរដងហើយមិនបានទៅបង្ហាញខ្លួន ។ ឥឡូវនេះ បញ្ហានេះត្រូវបានដោះស្រាយចប់សព្វគ្រប់ហើយ ។

ស្រដៀងគ្នាទៅនឹងការថ្លែងសុន្ទរកថារបស់លោក សម រង្ស៊ី វាក្យសព្ទរបស់លោក កឹម សុខា គឺពោរពេញទៅដោយការស្អប់ខ្ពើម នៅពេលដែលនិយាយទាក់ទងនឹងប្រទេសវៀតណាម និងប្រជាជនវៀតណាម ។ គាត់ថែមទាំងមានភាពអង់អាចក្នុងការថ្លែងជាសាធារណៈថាមន្ទីរសន្តិសុខខ្មែរក្រហម "ស២១" គឺជាការប្រឌិតឡើង ឬជា "ការបង្កើតឡើងរបស់វៀតណាម"ហើយដោយមូលហេតុដូចគ្នានេះ គាត់បានបដិសេធតថភាពនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ ប៉ុល ពត ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) បានកាត់ទោសអតីតប្រធានមន្ទីរ "ស២១" រួចហើយក៏ដោយ ។ ការបដិសេធដោយឥតលាក់លៀមនិងដោយចេតនាចំពោះការសម្លាប់រង្គាលនៅកម្ពុជាបែបនេះ

គួរតែត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ ដូចដែលបណ្តាបស្ចិមប្រទេសបានធ្វើ ចំពោះអ្នកដែលបានបដិសេធឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្រដៀងគ្នានេះ ។

គ) សមាជិកពីរនាក់ទៀតរបស់គណបក្សប្រឆាំងគឺសមាជិកព្រឹទ្ធសភាលោក ហុង សុខហួរ និងសមាជិកសភាលោក អ៊ុំ សំអាន ត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំនិងបទញុះញង់ឲ្យមានអំពើហិង្សា ។

លោក ហុង សុខហួរ បានផ្សព្វផ្សាយនិងចែកចាយសន្ធិសញ្ញាក្លែងក្លាយរវាងកម្ពុជានិងវៀតណាមដោយមានចេតនាបង្ហាញពីកិច្ចព្រមព្រៀងរំលាយព្រំដែនរវាងប្រទេសទាំងពីរ ។ ជនជាប់ចោទទាំងពីរបានអះអាងថាពួកគេគ្រាន់តែបានសម្តែងមតិរបស់ខ្លួនតែប៉ុណ្ណោះ ។ ការក្លែងបន្លំគឺមិនមែនការសម្តែងមតិទេ ហើយនៅក្នុងករណីនេះវាគឺជាការប៉ុនប៉ងដោយចេតនាបង្កអស្ថិរភាពប្រទេស ។ ការបំផ្លិចបំផ្លាញឯកសារនិងផ្តល់ព័ត៌មានក្លែងក្លាយពាក់ព័ន្ធទៅនឹងសន្តិសុខជាតិអាចចាត់ទុកជាអំពើក្បត់ជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌនៃបណ្តារដ្ឋប្រជាធិតេយ្យជាច្រើន ។ មាត្រា៤៥៦និង៤៥៧នៃក្រមព្រហ្មទណ្ឌកម្ពុជាបានចែងជាពិសេសចំពោះបទល្មើសបែបនេះ ។ ការផ្សាយសន្ធិសញ្ញាក្លែងក្លាយគឺជាទង្វើបដិសេធនិងជាការបំផ្លាញសន្ធិសញ្ញាពិតប្រាកដ ។ វាក៏ជាការផ្តល់ព័ត៌មានក្លែងក្លាយទៅលើស្ថានភាពនៃសន្ធិសញ្ញាឆ្នាំ ១៩៧៩ ដែលត្រូវបានចុះបញ្ជីជាមួយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (សូមមើលឯកសារក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ A/34/94-S/13101 និងការផ្សាយរបស់ក្រសួងការបរទេសបារាំង ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៩)។ មានភស្តុតាងយ៉ាងច្បាស់ដែលបញ្ជាក់ថាសន្ធិសញ្ញាដែលត្រូវបានផ្សព្វផ្សាយដោយលោក ហុង សុខហួរ គឺជាសន្ធិសញ្ញាក្លែងក្លាយ (មិនមែនគ្រាន់ជាការចោទប្រកាន់ថាក្លែងក្លាយទេ) ពោលគឺក្លែងក្លាយរហូតទៅដល់កម្រិតថា សូម្បីតែព្រំដែនរវាងកម្ពុជានិងវៀតណាមបានបាត់រូបរាងតែម្តង ។ អ្វីដែលគួរឲ្យសោកស្តាយគឺរដ្ឋាភិបាលបស្ចិមប្រទេសនៅតែបដិសេធមិនទទួលស្គាល់ភស្តុតាងផ្លូវការទាំងនេះ ។

ការប្រើពាក្យពេចន៍អភិភាពរបស់លោក អ៊ុំ សំអាន គឺជាការបំពានព្រហ្មទណ្ឌលើសេរីភាពនៃការបញ្ចេញមតិ និងការញុះញង់ឲ្យស្អប់ខ្ពើមជាតិសាសន៍ ដើម្បីគោលបំណងនៃការបោះឆ្នោតនិងការចំណេញនយោបាយ ។ ការញុះញង់ឲ្យមានអំពើហិង្សាគឺជាបទឧក្រិដ្ឋទោះបីជានៅក្នុងច្បាប់ប្រទេសណាក៏ដោយ។

សកម្មភាពល្មើសព្រហ្មទណ្ឌបែបនេះគឺជាមូលដ្ឋានសម្រាប់ការដកអភ័យឯកសិទ្ធិសភារបស់បុគ្គលទាំងពីររូបនេះ ។ នៅក្នុងបរិបទដ៏រសើបនៅក្នុងប្រទេសកម្ពុជាការញុះញង់អុជអាលមិនត្រឹមតែជាស់ឲ្យមានប្រតិកម្មជាសាធារណៈដ៏គ្រោះថ្នាក់ប៉ុណ្ណោះទេប៉ុន្តែថែមទាំងគម្រាមកំហែងដល់សន្តិសុខជាតិសន្តិភាពក្នុងតំបន់ព្រមទាំងធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងទ្វេភាគីរវាងប្រទេសជិតខាងទាំងពីរទៀតផង។

NGO និងអ្នកកាសែតបរទេសមិនបានរាយការណ៍ដោយស្មោះត្រង់អំពីការប្រព្រឹត្តរបស់គណបក្សប្រឆាំងទេ ។ ដោយផ្អែកលើបុរេនិច្ឆ័យដែលលំអៀងគាំទ្រគណបក្សប្រឆាំង ព័ត៌មានដែលចេញផ្សាយ

ទាំងឡាយគឺតែងតែគ្មានតុល្យភាព ពោលគឺនៅស្ងៀមស្ងាត់ចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយគណបក្សប្រឆាំងហើយផ្តល់ព័ត៌មានមិនពិតអំពីសកម្មភាពរបស់រដ្ឋាភិបាល ។

### ជ. អំពីការវាយតម្លៃសិទ្ធិមនុស្សនិងប្រជាធិបតេយ្យរបស់កម្ពុជា

តាមទស្សនៈរបស់ពួកគេស្តីអំពីស្ថានភាពសិទ្ធិមនុស្សនិងប្រជាធិបតេយ្យរបស់កម្ពុជាវាបានបង្ហាញយ៉ាងច្បាស់ថា ពួកបស្ចិមប្រទេសបានសន្មត់ថាក្រោយពីការបោះឆ្នោតដែលសម្របសម្រួលដោយអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាមានសមត្ថភាពពេញលេញដើម្បីប្រកាន់ខ្ជាប់ការអនុវត្តលទ្ធិប្រជាធិបតេយ្យដ៏ល្អឥតខ្ចោះរបស់បស្ចិមប្រទេស ។

នេះគឺជាការទាមទារឬ ជាការដាក់កំហិតហួសហេតុទៅលើប្រទេសមួយដូចជាកម្ពុជាដែលមានប្រវត្តិសាស្ត្រនៃកសាងរដ្ឋបែបទំនើបដ៏ខ្លីបំផុត ។

ស្រដៀងគ្នាទៅនឹងប្រទេសដែលធ្លាប់នៅក្រោមអាណានិគមអឺរ៉ុបមួយចំនួនដែរ លើកលែងប្រទេសដែលមានធនធានប្រេងសមត្ថភាពរដ្ឋរបស់ប្រទេសកម្ពុជាគឺនៅខ្សោយនៅឡើយមិនថា សមត្ថភាពស្ថាប័នច្បាប់ ឬ សង្គម ។

ទោះបីជាបន្ទាប់ពីមានការបោះឆ្នោតឆ្នាំ១៩៩៣ ក៏ដោយវាគឺជាការគិតបែបវីរវាយមួយក្នុងការធ្វើពុតជាយល់ថាប្រជាធិបតេយ្យនៅកម្ពុជានឹងលូតលាស់ទៅមុខ ដោយគ្មានហានិភ័យនៃការវិលត្រឡប់មកវិញនៃអំពើហិង្សា។ ការពិតជាក់ស្តែងគឺខ្មែរក្រហមបានបដិសេធមិនព្រមអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីសហើយបេសកម្មរបស់អង្គការសហប្រជាជាតិក៏បានបរាជ័យក្នុងការដោះស្រាយបញ្ហាដោយទុកឲ្យ ១ភាគ៣ នៃទឹកដីស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ មួយថ្ងៃនៅមុនពេលនៃការចាកចេញរបស់អង្គការសហប្រជាជាតិអ្នកនាំពាក្យរបស់ខ្លួនបានទទួលស្គាល់ថា ខ្មែរក្រហមបានបំផ្ទុះគ្រាប់បែកកំទេចស្ពានស្ទើរតែជារៀងរាល់ថ្ងៃ ។ នយោបាយពេលនោះនៅតែត្រូវបានគ្រប់គ្រងដោយក្រុមផ្សេងគ្នាដែលមានកម្លាំងប្រដាប់អាវុធនិងទឹកដីដែលគ្រប់គ្រងដោយស្វយ័ត ។ ការភ័យខ្លាចចំពោះការវិលត្រឡប់មកវិញនូវសង្គ្រាមស៊ីវិលគឺជាលទ្ធភាពដែលអាចកើតមានជារៀងរាល់ថ្ងៃ។

រហូតដល់ពេលមួយដែលរបបនយោបាយខ្មែរក្រហម និងកងកម្លាំងប្រដាប់អាវុធរបស់ពួកគេត្រូវបានរំលាយទាំងស្រុងនៅឆ្នាំ១៩៩៨ ទើបទីបំផុត កម្ពុជាអាចទទួលបានសន្តិភាពពេញលេញ និងអាចត្រួតត្រាលើទឹកដីទាំងមូលរបស់ខ្លួនបាន ។ ការធ្វើសន្តិភាវូបនីយកម្មដែលប្រសូតចេញពីលទ្ធផលនៃគោលនយោបាយឈ្នះ-ឈ្នះរបស់រាជរដ្ឋាភិបាល គឺពិតជាជោគជ័យជាប្រវត្តិសាស្ត្រមួយដែលមិនធ្លាប់មានពីមុនមក ។ ប៉ុន្តែ គួរឲ្យសោកស្តាយដែលប្រព័ន្ធផ្សព្វផ្សាយ និងមន្ត្រីការទូតបស្ចិមប្រទេសកម្រ ឬ ក៏មិនដែលបានរំឭកឡើងវិញ ឬ លើកសរសើរពីគោលនយោបាយនេះទេ ។

ប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជាបានបង្ហាញថា កម្ពុជាមានពេលវេលានិងបរិយាកាសដ៏តិចតួចបំផុត សម្រាប់ការងារកសាងរដ្ឋនិងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម ។

យ៉ាងណាក្តី កម្ពុជាដឹងច្បាស់ណាស់អំពីចំណុចខ្វះខាតខាងស្ថាប័ន និងសមត្ថភាពទន់ខ្សោយរបស់ខ្លួន ។ នៅក្នុងរយៈកាលសន្តិភាពដ៏សែនខ្លីមួយនេះ កម្ពុជាបានខិតខំខ្នះខ្នែងពង្រឹងសមត្ថភាពរដ្ឋ ផ្តល់នូវជីវភាពរស់នៅកាន់តែល្អប្រសើរ និងវិបុលភាពជូនប្រជាជនរបស់ខ្លួន និងធានាឲ្យបាននូវការវិវត្តឆ្ពោះទៅរកប្រជាធិបតេយ្យភាវូបនីយកម្មពេញលេញ ដោយរលូននិងដោយសន្តិភាព ។

ក្នុងបរិការបែបនេះ ការរក្សាស្ថិរភាពនិងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មប្រកបដោយសន្តិភាពគឺជាការផលប្រយោជន៍ដាច់ខាតរបស់កម្ពុជា ។ កម្ពុជាមិនចង់បង្កើតបញ្ហាសម្រាប់ពិភពលោកសាជាថ្មីម្តងទៀត ហើយក៏មិនចង់ឲ្យមានជនភៀសខ្លួនរាប់សែននាក់របស់ខ្លួនហូរចូលទៅកាន់អឺរ៉ុបនិងសហរដ្ឋអាមេរិក ដែលកំពុងតែព្យាយាមបិទទ្វារប្រទេសមិនឲ្យមានការហូរចូលយ៉ាងគំហុកនូវជនភៀសខ្លួនដែលជាជនរងគ្រោះនៃ "បដិវត្តន៍ពណ៌" និង "ការផ្លាស់ប្តូររបបដោយបង្ខំ" ដែលទាំងនេះតែងតែត្រូវបានគេពណ៌នាថាធ្វើឡើងដើម្បី "សិទ្ធិមនុស្សនិងប្រជាធិបតេយ្យ" ។

ការដាក់កំហុស ការរិះគន់ការដាក់ឲ្យនៅឯកោ ការគម្រាមបិទទីផ្សារនិងដាក់ទណ្ឌកម្ម ឥតឈប់ឈរ មិនអំណោយផលដល់ការស្វែងរកដំណោះស្រាយណាមួយនោះទេ ។ បស្ចិមប្រទេសគួរតែជួយកម្ពុជាស្វែងរកដំណោះស្រាយសម្រាប់ប្រជាធិបតេយ្យភាវូបនីយកម្មប្រកបដោយសន្តិភាព ឈរលើការគោរពគ្នា និងការយោគយល់គ្នាទៅវិញទៅមក ។

ជំនួសឲ្យការធ្វើឲ្យរាំងស្ទះដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ឈរលើគោលការណ៍នីតិរដ្ឋ បណ្តារដ្ឋាភិបាល និងស្ថាប័នបរទេសដែលបានជ្រើសរើសយកការដាក់កំហុសចំពោះស្ថាប័នស្របច្បាប់ ពួកគេគួរតែលើកទឹកចិត្តដល់គណបក្សប្រឆាំងឲ្យគោរពរដ្ឋធម្មនុញ្ញ ប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិបតេយ្យ ប្រកាន់នូវឥរិយាបថនយោបាយស៊ីវិល័យ ព្រមទាំងចូលរួមនៅក្នុងកិច្ចសន្ទនាគោលនយោបាយ ជាជាងបន្តការធ្វើនយោបាយប្រជាភិថុតដោយគ្មានការទទួលខុសត្រូវ បង្កការស្អប់ខ្ពើមជាតិសាសន៍ ញុះញង់ឲ្យមានភាពចលាចលក្នុងសង្គម និងការបរិហាកេរ្តិ៍អ្នកដទៃ។

* * * * * * * * * *